សលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារស្តីពីស្ថាប័ន ៖ ក្រុមប្រឹក្សាធម្មនុញ្ញ

ស្ថាប័ន ៖ ក្រុមប្រឹក្សាធម្មនុញ្ញ

រូបភាពរួម ៖ ក្រុមប្រឹក្សាធម្មនុញ្ញ មិនបានអនុវត្តតួនាទីរបស់ខ្លួនដើម្បីការពារការគោរពរដ្ឋធម្មនុញ្ញនោះទេ។ ទំនាក់-ទំនងផ្នែកនយោបាយយ៉ាងរឹងមាំ យុត្តាធិការដែលនៅមានកម្រិត និងតម្រូវការផ្នែកនីតិវិធីដ៏សុគស្មាញបានធ្វើឲ្យ ក្រុម-ប្រឹក្សាធម្មនុញ្ញទៅជាគ្មានប្រសិទ្ធភាព - សាធារណៈជនទូទៅគ្មានឱកាសក្នុងការទទួលបាននូវព័ត៌មានរបស់ស្ថាប័ននេះ និងទទួលរងឥទ្ធិពលនយោបាយពីអំណាចនីតិប្រតិបត្តិ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ ពន្យល់ពីតួនាទីដែលត្រូវបានចាត់តាំងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) យោងតាមច្បាប់កម្ពុជា តួនាទីពិតប្រាកដនៃស្ថាប័ន និងមតិយោបល់ដើម្បីការកែលម្អ។ សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ (“អង្គការ”) ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

តើក្រុមប្រឹក្សាធម្មនុញ្ញគឺជាអ្វី?

ទូទៅ

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានបង្កើតឡើងដោយ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ឆ្នាំ១៩៩៣ ដើម្បីទទួលភារកិច្ចការពារការគោរពច្បាប់រដ្ឋធម្មនុញ្ញ និងបកស្រាយច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយណាដែលបានអនុម័តដោយរដ្ឋសភា និងត្រួតពិនិត្យដោយព្រឹទ្ធសភា។ យុត្តាធិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញក៏មានទាំងសិទ្ធិទទួល និងសម្រេចលើករណីវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាផងដែរ។ ស្របពេលដែលមាត្រា១៥០ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថាច្បាប់ និងសេចក្តីសម្រេចដោយស្ថាប័នរដ្ឋត្រូវតែស្របតាមរដ្ឋធម្មនុញ្ញជាដាច់ខាត ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បែរជាកម្រិតតួនាទីនៃក្រុមប្រឹក្សាធម្មនុញ្ញក្នុងការធានានូវធម្មនុញ្ញភាពនៃសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋឲ្យត្រឹមតែពិចារណាលើករណីដែលដាក់ជូនដោយប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងនីតិវិធីផ្នែកច្បាប់ទៅវិញ។

សមាសភាព

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកទាំងអស់ចំនួន៩រូប ដែលសមាជិកចំនួន៣រូប តែងតាំងដោយព្រះមហាក្សត្រ សមាជិកចំនួន៣រូប តែងតាំងដោយរដ្ឋសភាជាតិ និងសមាជិកចំនួន៣រូបផ្សេងទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ អាណត្តិរបស់សមាជិកគឺរយៈពេល ៩ឆ្នាំ ប៉ុន្តែចំនួនមួយភាគបីនៃសមាជិកត្រូវបានតែងតាំងជាថ្មីរៀងរាល់៣ឆ្នាំម្តង។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានចាត់តាំងជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត។ ចំណុចនេះសំខាន់ខ្លាំងណាស់ដោយសារតែក្រុមប្រឹក្សានេះ ត្រូវត្រួតពិនិត្យមើលច្បាប់ដែលអនុម័តដោយរដ្ឋសភា ហើយសមត្ថកិច្ចមួយនេះអាចនឹងត្រូវរងការយាយីប្រសិនបើក្រុមប្រឹក្សាមានការពាក់ព័ន្ធ ឬត្រូវគ្រប់គ្រងដោយនយោបាយ។ ជាទ្រឹស្តី មានធាតុផ្សំនៃការបែងចែកអំណាចក្នុងប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែល ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថាមុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា ឬរដ្ឋសភា ប្រធាន ឬអនុប្រធាននៃ

គណបក្សនយោបាយ ឬសហជីព ឬចៅក្រមក្នុងតំណែង។ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចែងទៀតថាសមាជិកទាំងអស់មិនត្រូវបំពេញមុខតំណែងនយោបាយ ឬមុខរបរផ្សេងទៀតក្នុងអាណត្តិរបស់ខ្លួនឡើយ។ ប៉ុន្តែ សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញទាំងក្នុងអតីតកាល និងបច្ចុប្បន្នមានមុខតំណែងនៅក្នុងសេវាសាធារណៈ ជាពិសេសមានទំនាក់ទំនងជាមួយគណបក្សកាន់អំណាច។ មុខតំណែងនៃសមាជិកជាក់លាក់របស់ក្រុមប្រឹក្សាធម្មនុញ្ញបានចោទជាសំណួរពាក់ព័ន្ធនឹងអព្យាក្រឹតភាពរបស់ពួកគាត់។

ភារកិច្ច

ក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចសំខាន់ពីរគឺ ៖ ទីមួយ ពិនិត្យមើលនូវធម្មនុញ្ញភាពរបស់ពង្រាង-ច្បាប់ ច្បាប់ និងក្រមរដ្ឋបាលដែលមានស្រាប់ និងទីពីរ សម្រេចលើវិវាទកម្មក្នុងការបោះឆ្នោត។ ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងនោះឡើយ។ ធម្ម-នុញ្ញភាពនៃច្បាប់អាចត្រូវបានត្រួតពិនិត្យដោយមានសំណើ ឧទាហរណ៍ ពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធ-សភា ប្រធានរដ្ឋសភាជាតិ នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន សមាជិករដ្ឋសភាជាតិមួយភាគដប់ ឬតុលាការ។ ប្រជាពលរដ្ឋពាក់ព័ន្ធនឹងនីតិវិធីច្បាប់ដែលពិចារណាថាមាត្រាណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័នណាមួយបានរំលោភបំពានលើសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់ពួកគាត់ ពួកគាត់អាចលើកយកនូវធម្មនុញ្ញភាពនៃច្បាប់ ឬសេចក្តីសម្រេចដាក់ជូនទៅតុលាការបាន។ តុលាការនឹងបញ្ជូនបណ្តឹងនេះទៅតុលាការកំពូលប្រសិនបើពាក្យបណ្តឹងនោះមានហេតុផល។ លើកលែងតែករណីដែលពាក្យបណ្តឹងដែលមិនអាចទទួលយកបាន តុលាការកំពូលត្រូវតែបញ្ជូនពាក្យបណ្តឹងនេះទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ទោះបីជាប្រជាពលរដ្ឋមិនបានពាក់ព័ន្ធនឹងនីតិវិធីផ្នែកច្បាប់ណាមួយក៏ដោយ ក៏ពួកគាត់អាចមានសិទ្ធិលើកយកបញ្ហាធម្មនុញ្ញភាពរបស់ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ឬស្នើសុំឲ្យក្រុមប្រឹក្សាធ្វើការបកស្រាយច្បាប់នោះបានដែរ។ សិទ្ធិទាំងនេះមិនមែនមានន័យថាពួកគាត់អាចទៅរកក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់នោះទេ ប៉ុន្តែពួកគាត់ត្រូវតែដាក់ពាក្យបណ្តឹងតាមរយៈបុគ្គលដែលមានសិទ្ធិស្របច្បាប់ណាមួយតាមការពណ៌នាខាងលើ។ តាមរយៈកំណត់សម្គាល់ខាងលើ សំណួរពាក់ព័ន្ធនឹងធម្មនុញ្ញភាពនៃសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋដែលប៉ះពាល់ដល់សិទ្ធិប្រជាពលរដ្ឋនឹងត្រូវបានលើកឡើងដោយប្រជាពលរដ្ឋពាក់ព័ន្ធនឹងនីតិវិធីផ្នែកច្បាប់ប៉ុណ្ណោះ។

ប្រសិទ្ធភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការងារមួយចំនួនមកទល់ពេលបច្ចុប្បន្នក្នុងការបញ្ជាក់បញ្ញត្តិនៃរដ្ឋ-ធម្មនុញ្ញ។ ឧទាហរណ៍ ក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សានេះបានបញ្ជាក់ថាអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ បង្កើតជាផ្នែកមួយនៃច្បាប់ដែលតុលាការជំនុំជម្រះគួរតែពិចារណាដល់ សេចក្តីសម្រេចដ៏សំខាន់មួយនេះស្តីពីការបញ្ចូលកតិកា-សញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិ។ តាមរយៈគេហទំព័ររបស់ក្រុម-ប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលជាង១០ឆ្នាំ ក្រុមប្រឹក្សានេះបានពិចារណាលើករណីចំនួន២១ ពាក់ព័ន្ធនឹងការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ករណីចំនួន៥២ ពាក់ព័ន្ធនឹងការត្រួតពិនិត្យធម្មនុញ្ញភាព និងករណីចំនួន៤៦ ជាវិវាទផ្នែកបោះឆ្នោត។ មានករណីចំនួន៤៨ ត្រូវបានបដិសេធដោយសារ "មិនបានបំពេញគ្រប់លក្ខខណ្ឌ" ឬការពិតគឺពាក្យស្នើសុំទាំងនោះមិនបានបំពេញតាមតម្រូវការទម្រង់ផ្នែកច្បាប់។ ទោះបីជាមានបញ្ហាជាច្រើនទាក់ទងនឹងការរំលោភបំពានដីធ្លី និងសំណួរពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ ក៏បញ្ហាទាំងពីរនេះមិនដែលត្រូវបានយកមកវែកញែក ឬលើកយកមក ដើម្បីប្រើប្រាស់នូវយន្តការរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះទេ។ ប្រជាពលរដ្ឋខ្មែរសាមញ្ញ និងសូម្បីតែអ្នកជំនាញផ្នែកច្បាប់ មិនបានដឹង

ច្បាស់ពីនីតិវិធី ដូច្នេះទើបគ្មានញត្តិណាដែលត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងករណីទាំងនេះទេ។ ប្រជាពលរដ្ឋដទៃទៀត ប្រហែលជាមានការសង្ស័យចំពោះឯករាជ្យភាព និងភាពអព្យាក្រឹតជាខ្លាំងដែលធ្វើឲ្យមានភាពមិនជឿជាក់ដល់ក្រុមប្រឹក្សានេះសម្រេចលើករណីសំខាន់ៗពាក់ព័ន្ធនឹងធម្មនុញ្ញភាពនៃសកម្មភាពរបស់អង្គនីតិប្រតិបត្តិ។

សេចក្តីសន្និដ្ឋាន/អនុសាសន៍

ដើម្បីឲ្យក្រុមប្រឹក្សាធម្មនុញ្ញ អាចធ្វើការត្រួតពិនិត្យបានយ៉ាងមានប្រសិទ្ធភាពលើអំណាចនីតិប្រតិបត្តិ ម.ស.ម.ក បានផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- ត្រូវតែមានការផ្លាស់ប្តូរអាណត្តិរបស់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីបង្កើននូវភាពសកម្មរបស់ក្រុមប្រឹក្សា និងអនុញ្ញាតឲ្យក្រុមប្រឹក្សានេះអាចធ្វើសកម្មភាពដោយផ្ទាល់ក្នុងការការពាររដ្ឋធម្មនុញ្ញ ដោយមិនរង់ចាំការបញ្ជូនសំណើពីភាគីនានាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនោះទេ។
- គួរតែពង្រីកយុត្តាធិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញបន្ថែម ដែលមិនមែនត្រឹមតែគ្របដណ្តប់លើសកម្មភាពរបស់នីតិប្រតិបត្តិ ប៉ុន្តែគឺសេចក្តីសម្រេចទាំងឡាយរបស់ស្ថាប័នរដ្ឋ ដែលបានដាក់ស្នើឡើងដោយបុគ្គលណាក៏ដោយ។
- សាធារណជន និងតំណាងរាស្ត្រគួរតែពិចារណាប្រើប្រាស់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា។ ចំណុចនេះតម្រូវឲ្យមានការយល់ដឹងពីនីតិវិធីឲ្យបានទូលាយជាងនេះសម្រាប់ប្រជាពលរដ្ឋទូទៅ ដូច្នេះសាធារណជនភាគច្រើន និងអ្នកជំនាញផ្នែកច្បាប់ដែលជាតំណាងឲ្យប្រជាពលរដ្ឋ អាចទាញយកផលប្រយោជន៍ពីនីតិវិធីទាំងនោះដើម្បីការពារសិទ្ធិប្រជាពលរដ្ឋ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (០) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.org **ឬកញ្ញា សាណា ហ្គោស (+៨៥៥ (០) ៨៩ ៦១ ៥៣ ៣៤ ឬអ៊ីម៉ែល៖** sana.ghouse@cchrcambodia.org **។**